# « វិញ្ញាណនៃវិវរណៈ »

អែលឌើរ ដេវីឌ អេ បែដណា
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*វិញ្ញាណនៃវិវរណៈគឺមានពិត —ហើយអាច និងធ្វើការនៅក្នុងជីវិតរស់នៅរបស់យើងម្នាក់ៗ និងនៅក្នុងសាសនាចក្រ ។*

ខ្ញុំសូមអញ្ជើញអ្នកឲ្យពិចារណានូវបទពិសោធន៍ចំនួនពីរ ដែលយើងទាំងអស់គ្នា ឬដែលយើងភាគច្រើនមានជាមួយនឹងពន្លឺ ។ បទពិសោធន៍ទីមួយ បានកើតឡើងនៅពេលយើងចូលទៅក្នុងបន្ទប់ងងឹត ហើយបើកភ្លើង ។ សូមចាំថា ពន្លឺបើកភ្លាមចាំងបំភ្លឺពេញបន្ទប់ ហើយធ្វើឲ្យភាពងងឹតរលាយបាត់ទៅ ។ អ្វីដែលមើលមិនឃើញ ហើយមិនច្បាស់កាលពីមុន ត្រូវបានមើលឃើញច្បាស់ និងស្គាល់បាន ។ បទពិសោធន៍នេះ ត្រូវបានពិពណ៌នាដោយការស្គាល់ពន្លឺភ្លាមៗ ហើយប្រកបដោយថាមពល ។

បទពិសោធន៍ទីពីរ កើតឡើងនៅពេលយើងមើលមេឃងងឹតទៀបភ្លឺ ។តើអ្នកមានចាំថា ពន្លឺបានកើនឡើងបន្តិចម្តងៗស្ទើរតែមិនដឹងនៅឯជើងមេឃមែនទេ ? វាផ្ទុយនឹងការបើកភ្លើងនៅក្នុងបន្ទប់ងងឹត ។ ពន្លឺមកពីព្រះអាទិត្យរះមិនភ្លឺភ្លាម ៗ នោះទេ ។ ប៉ុន្តែ ថាមពលពន្លឺកើនឡើងបន្តិចម្តងៗ ដោយខ្ជាប់ខ្ជួន រួចហើយភាពងងឹតនៃពេលយប់ ត្រូវបានជំនួសដោយពន្លឺនៃពេលព្រឹក ។ នៅទីបំផុត ព្រះអាទិត្យបានរះនៅលើជើងមេឃ ។ ប៉ុន្តែរូបភាពភស្តុតាងនៃការជិតរះឡើងរបស់ព្រះអាទិត្យ គឺមើលឃើញរាប់ម៉ោង មុនពេលព្រះអាទិត្យបានលេចមកលើផ្ទៃមេឃជាក់ស្តែង ។ បទពិសោធន៍នេះ ត្រូវបានពិពណ៌នាដោយការស្គាល់នៃពន្លឺភ្លឺបន្តិចម្តង ៗ ។
តាមរយៈបទពិសោធន៍អំពីពន្លឺធម្មតាពីរនេះ យើងអាចរៀនច្រើនអំពីវិញ្ញាណនៃវិវរណៈ ។ ខ្ញុំអធិស្ឋានសុំឲ្យព្រះវិញ្ញាណបរិសុទ្ធនឹងបំផុសគំនិត ហើយបង្រៀនយើង នៅពេលយើងផ្តោតទៅលើវិញ្ញាណនៃវិវរណៈ និងគំរូជាមូលដ្ឋាន ដែលត្រូវបានទទួលវិវរណៈក្នុងពេលឥឡូវនេះ ។

## *វិញ្ញាណនៃវិវរណៈ*

វិវរណៈ គឺជាការទំនាក់ទំនងមកពីព្រះទៅកាន់កូនចៅរបស់ទ្រង់នៅលើផែនដី ហើយជាពរជ័យដ៏មហិមាមួយ ដែលភ្ជាប់ជាមួយនឹងអំណោយទាន និងជាដៃគូដ៏ខ្ជាប់ខ្ជួននៃព្រះវិញ្ញាណបរិសុទ្ធ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនថា « ព្រះវិញ្ញាណបរិសុទ្ធជាអ្នកទទួលវិវរណៈ » ហើយ « គ្មានមនុស្សណាម្នាក់ អាចទទួលព្រះវិញ្ញាណបរិសុទ្ធ ដោយពុំបានទទួលវិវរណៈនោះទេ » ( *Teachings of Presidents of the Church: Joseph Smith* [ ឆ្នាំ 2007 ] ទំព័រ 132 ) ។

វិញ្ញាណនៃវិវរណៈមានសម្រាប់មនុស្សគ្រប់រូប ដែលទទួលបាន នូវពិធីបរិសុទ្ធនៃការសង្គ្រោះនៃពិធីបុណ្យជ្រមុជទឹក ដោយការជ្រមុជសម្រាប់ការផ្តាច់បាប និងការដាក់ដៃលើសម្រាប់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ — និងអ្នកដែលធ្វើកិច្ចការដោយសេចក្តីជំនឿ ដើម្បីបំពេញតាមបង្គាប់នៃបព្វជិតភាព ដើម្បី « ទទួលព្រះវិញ្ញាណបរិសុទ្ធ » តាមរយៈសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវ ។ ពរជ័យនេះ មិនត្រូវបានកំណត់ចំពោះតែអ្នកមានសិទ្ធិអំណាចជាអធិបតីនៃសាសនាចក្រទេ ប៉ុន្តែវាជាកម្មសិទ្ធិ ហើយគួរតែប្រតិបត្តិនៅក្នុងជីវិតបុរសស្រ្តី និងកុមារគ្រប់រូប ដែលឈានចូលដល់វ័យដឹងខុសត្រូវ ហើយចូលទៅក្នុងសេចក្តីសញ្ញាដ៏ពិសិដ្ឋទាំងឡាយ ។ បំណងប្រាថ្នាដោយស្មោះ និងភាពស័ក្តិសម អញ្ជើញវិញ្ញាណនៃវិវរណៈមកក្នុងជីវិតរស់នៅរបស់យើង ។

យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ទទួលបានបទពិសោធន៍ដ៏មានតម្លៃអំពីវិញ្ញាណនៃវិវរណៈ នៅពេលពួកគាត់បកប្រែព្រះគម្ពីរមរមន ។ បងប្អូនប្រុសទាំងពីររូបនេះ បានរៀនដឹងថា ពួកគាត់អាចទទួលនូវចំណេះដឹងគ្រប់យ៉ាងដែលចាំបាច់ ដើម្បីបញ្ចប់កិច្ចការរបស់ពួកគាត់ បើសិនជាពួកគាត់សុំដោយសេចក្តីជំនឿ ដោយដួងចិត្តស្មោះត្រង់ ហើយជឿថាពួកគាត់នឹងបានទទួល ។ ហើយយូរៗទៅ ពួកគាត់យល់កាន់តែច្រើនពីវិញ្ញាណនៃវិវរណៈថាជាដំណើរការធម្មតាដូចជាគំនិត និងអារម្មណ៍ ដែលមានមកក្នុងគំនិត និងដួងចិត្តរបស់យើង ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ( សូមមើល គ. និង ស. 8:1–2; 100:5–8) ។ ដូចដែលព្រះអម្ចាស់បានបង្រៀនពួកគាត់ថា « ឥឡូវនេះ មើលចុះ នេះជាវិញ្ញាណនៃវិវរណៈ មើលចុះ នេះជាវិញ្ញាណដែលលោកម៉ូសេ បាននាំកូនចៅអ៊ីស្រាអែល ឆ្លងសមុទ្រក្រហមលើដីគោក ។

ហេតុដូច្នេះហើយ នេះជាអំណោយទានរបស់អ្នក ចូរអនុវត្តចុះ » ( គ. និង ស. 8:3–4 ) ។ខ្ញុំចង់សង្កត់ធ្ងន់លើឃ្លា « ចូរអនុវត្តចុះ » ដែលជាប់ទាក់ទងនឹងវិញ្ញាណនៃវិវរណៈ ។ នៅក្នុងគម្ពីរ ឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធជាញឹកញាប់ ត្រូវបានពិពណ៌នាថាជា « សម្លេងតូចរហៀង » ( នីហ្វៃទី 1 17: 45 ពង្សាវតាក្សត្រទី 1 19:12 និង នីហ្វៃទី 3 11:3 ) និងជា « សម្លេងរហៀងៗនៃភាពស្រទន់ឥតខ្ចោះ » ( ហេលេមិន 5:30 ) ។ដោយសារព្រះវិញ្ញាណខ្សឹបប្រាប់យើង

ដោយស្រទន់ និងដោយផ្ចិតផ្ចង់ វាងាយស្រួលនឹងយល់ថាហេតុអ្វីបានជាយើងគួរតែចៀសវាងពីប្រព័ន្ធព័ត៌មានមិនសមរម្យ រូបអាសគ្រាម និងសារធាតុ និងអាកប្បកិរិយា ដែលនាំឲ្យមានគ្រោះថ្នាក់ និងញៀន ។ ឧបករណ៍របស់មាសត្រូវទាំងនេះ អាចធ្វើឲ្យអន់ថយ ហើយបំផ្លាញសមត្ថភាពរបស់យើង ក្នុងការស្គាល់ និងឆ្លើយតបចំពោះសារលិខិតដ៏ស្រទន់មកពីព្រះ ដែលបាននាំមកដោយព្រះចេស្ដា នៃព្រះវិញ្ញាណរបស់ទ្រង់បន្ដិចម្ដងៗ ។ យើងម្នាក់ៗ គួរតែគិតដោយហ្មត់ចត់ និងពិចារណាប្រកបដោយការអធិស្ឋានអំពីរបៀបដែលយើងអាចបដិសេធការបោកបញ្ឆោតរបស់អារក្ស ហើយ « អនុវត្ត » ដោយសុចរិត នូវវិញ្ញាណនៃវិវរណៈនៅក្នុងជីវិតរស់នៅផ្ទាល់ខ្លួនរបស់យើង និងនៅក្នុងក្រុមគ្រួសារ ។

***គំរូនៃវិវរណៈ***

វិវរណៈត្រូវបានបង្ហាញតាមរបៀបផ្សេងៗគ្នា ឧទាហរណ៍ រួមមាន សុបិន ការនិមិត្ត ការសន្ទនាជាមួយនឹងសារទូតពីស្ថានសួគ៌ និង ការបំផុសគំនិត ។ វិវរណៈមួយចំនួនត្រូវបានទទួលភ្លាមៗ ហើយ ប្រកបដោយអំណាច វិវរណៈមួយចំនួនត្រូវបានស្គាល់បន្តិចម្តងៗ ដោយស្រទន់ ។ បទពិសោធន៍អំពីពន្លឺចំនួនពីរ ដែលខ្ញុំបានពិពណ៌នា ជួយយើងឲ្យយល់កាន់តែច្បាស់ នូវគំរូជាមូលដ្ឋានទាំងពីរ អំពីវិវរណៈនេះ ។

ពន្លឺភ្លើងដែលបើកនៅក្នុងបន្ទប់ងងឹត គឺដូចជាការទទួលសារលិខិតមកពីព្រះភ្លាមៗទាំងស្រុង និងទាំងអស់ក្នុងពេលតែមួយ ។ ភាគច្រើនយើងបានទទួលបទពិសោធន៍ពីគំរូនៃវិវរណៈនេះ នៅពេលយើងទទួលបានចម្លើយចំពោះការអធិស្ឋានដោយស្មោះ ឬត្រូវបានផ្ដល់ឲ្យជាមួយនឹងការដឹកនាំ ឬ ការការពារដែលចាំបាច់ ស្របទៅតាមព្រះទ័យ និងពេលវេលារបស់ព្រះ ។ ការពិពណ៌នាអំពីការបង្ហាញភ្លាមៗ និងប្រកបដោយថាមពលនេះ មាននៅក្នុងព្រះគម្ពីរ រៀបរាប់នៅក្នុងប្រវត្តិសាស្ត្រសាសនាចក្រ និងជាភស្តុតាងនៅក្នុងជីវិតរស់នៅរបស់យើងផ្ទាល់ ។ តាមពិតអព្ភូតហេតុដ៏អស្ចារ្យទាំងនេះ ពិតជាកើតមានមែន ។ ទោះជាយ៉ាងណាក៏ដោយ គំរូនៃវិវរណៈនេះ កើតឡើងដោយកម្រ ជាជាងកើតមានតាមធម្មតា ។

ពន្លឺភ្លឺបន្តិចម្តងៗមកពីព្រះអាទិត្យរះ គឺដូចជាការទទួលសារលិខិតមកពីព្រះ « មួយបន្ទាត់ម្តងៗ មួយសិក្ខាបទម្តងៗ » ( នីហ្វៃទី 2 28:30 ) ។ជាញឹកញាប់បំផុត វិវរណៈកើតមានបន្តិចម្តងៗ ក្នុងពេលមួយ ហើយត្រូវបានទទួលស្របតាមបំណងប្រាថ្នា ភាពសក្តិសម និងការរៀបចំរបស់យើង ។ ទំនាក់ទំនងមកពីព្រះវរបិតាសួគ៌បន្តិចម្តងៗ និងដោយស្រទន់នេះ « ចុះមកលើ [ ព្រលឹងរបស់យើង ] ដូចជាទឹកសន្សើមចុះពីលើមេឃ » ( គ. និង ស. 121:45 ) ។ គំរូនៃវិវរណៈនេះគំរូជាក់លាក់នៃវិវរណៈនេះ កើតមានតាមធម្មតា ជាងដោយកម្រ ហើយជាភស្តុតាង នៅក្នុងបទពិសោធន៍របស់នីហ្វៃ នៅពេលគាត់ព្យាយាមជាច្រើនដងផ្សេងៗគ្នា មុនពេលទទួលបានផ្ទាំងចំណារពីឡាបាន់ ដោយជោគជ័យ (សូមមើល នីហ្វៃទី 1 3–4) ។ នៅទីបំផុត គាត់ត្រូវបានដឹកនាំ ដោយព្រះវិញ្ញាណទៅកាន់ទីក្រុងយេរូសាឡិម « ដោយមិនដឹងជាមុនសោះឡើយថាតើ [ គាត់ ] នឹងត្រូវធ្វើអ្វីខ្លះ ( នីហ្វៃទី 1 4:6 ) ។ហើយគាត់មិនចេះសង់សំពៅតាមរបៀបរបស់មនុស្សទាំងអស់ ក្នុងពេលតែមួយនោះទេ ប៉ុន្តែគាត់ត្រូវបានបង្ហាញដោយព្រះអម្ចាស់ « ពីរបៀបដែលគាត់ត្រូវធ្វើវាងសំពៅ ( នីហ្វៃទី 1 18:1 ) ។

ទាំងក្នុងប្រវត្តិសាសនាចក្រ និងជីវិតផ្ទាល់ខ្លួនរបស់យើង គឺត្រូវបានបំពេញទៅដោយគំរូនៃលំនាំរបស់ព្រះអម្ចាស់ក្នុងការទទួលវិវរណៈ « មួយបន្ទាត់ម្តងៗ មួយសិក្ខាបទម្តងៗ » ។ ឧទាហរណ៍ សេចក្តីពិតជាគ្រឹះនៃដំណឹងល្អដែលបានស្តារឡើងវិញ មិនត្រូវបានប្រគល់ដល់ព្យាការីយ៉ូសែប ស៊្មីធ ទាំងអស់ក្នុងពេលតែមួយ នៅក្នុងព្រៃពិសិដ្ឋនោះទេ ។ ទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបានទាំងនេះ ត្រូវបានបើកសម្តែង ជាស្ថានភាពដែលតម្រូវឲ្យមាន និងនៅពេលវេលាត្រឹមត្រូវ ។

ប្រធាន យ៉ូសែប អែហ្វ ស៊្មីធ បានពន្យល់អំពីរបៀបដែលគំរូនៃវិវរណៈនេះ បានកើតមានឡើងនៅក្នុងជីវិតរបស់គាត់ ។

« កាលពីក្មេង ...ខ្ញុំតែងតែ ...សុំឲ្យព្រះអម្ចាស់បង្ហាញដល់ខ្ញុំនូវរឿងអស្ចារ្យមួយចំនួន ដើម្បីខ្ញុំអាចទទួលបានទីបន្ទាល់មួយ ។ ប៉ុន្តែព្រះអម្ចាស់បានដកភាពស្ងប់ស្ងែងចេញពីខ្ញុំ ហើយបង្ហាញដល់ខ្ញុំនូវសេចក្តីពិត មួយបន្ទាត់ម្តង ៗ ... ហូតដល់ទ្រង់ធ្វើឲ្យខ្ញុំដឹងសេចក្តីពិត ចេញមកពីក្រយៅក្បាលរបស់ខ្ញុំ ហូតដល់ចុងជើង ហើយហូតដល់ភាពសង្ស័យ និងភាពភ័យខ្លាច ត្រូវបានដកចេញទាំងស្រុងពីខ្ញុំ។ ទ្រង់មិនបានបញ្ជូនទេវតាមកពីស្ថានសួគ៌ដើម្បីធ្វើការនេះទេ ហើយទ្រង់ក៏មិនមានបន្ទូលដូចជាសម្លេងត្រែរបស់មហាទេវតាដែរ ។ តាមរយៈការខ្សឹបប្រាប់ដោយសម្លេងតូចរហៀងរបស់ព្រះវិញ្ញាណនៃព្រះដ៏មានព្រះជន្មរស់ នោះទ្រង់បានប្រទានដល់ខ្ញុំនូវទីបន្ទាល់ដែលខ្ញុំមាននេះ ។ ហើយតាមរយៈគោលការណ៍ និងអំណាចនេះ ទ្រង់នឹងផ្តល់ទៅគ្រប់កូនចៅរបស់ទ្រង់ នូវចំណេះដឹងពីសេចក្តីពិត ដែលនឹងស្ថិតនៅជាមួយនឹងពួកគេ ហើយវានឹងធ្វើឲ្យពួកគេស្គាល់សេចក្តីពិត ដូចជាព្រះបានដឹង ហើយធ្វើតាមព្រះទ័យរបស់ព្រះវរបិតា ដូចជាព្រះគ្រីស្ទបានធ្វើ ។ ហើយគ្មានចំនួននៃការបង្ហាញដ៏អស្ចារ្យណា នឹងសម្រេចបាននូវការណ៍នេះទេ » ( *Gospel Doctrine: Selections from the Sermons and Writings of Joseph F. Smith* ឆ្នាំ 1986 ទំព័រ 7 ) ។

ក្នុងនាមយើងជាសមាជិកនៃសាសនាចក្រ យើងមានទំនោរចង់គូសបញ្ជាក់អំពីការបង្ហាញដ៏អស្ចារ្យ និងការបង្ហាញខាងវិញ្ញាណជាក់ស្តែងខ្លាំងណាស់ ដែលយើងអាចនឹងភ្លេចអរគុណ ហើយមើលរំលងគំរូជាតួយ៉ាង ដែលព្រះវិញ្ញាណបរិសុទ្ធ សម្រេចកិច្ចការរបស់ទ្រង់ ។ « វិធីនេះងាយពេក » ( នីហ្វៃទី 1 17:41 ) ក្នុងការទទួល ការបង្ហាញខាងវិញ្ញាណតូចៗបន្ថែមដែលយូរៗទៅ សរុបទៅ បង្កើតបានជាចម្លើយដែលចង់បាន ឬការដឹកនាំដែលយើងត្រូវការអាចធ្វើឲ្យយើងមើល « ហួសទីដៅ » ( យ៉ាកុប 4:14) ។

ខ្ញុំបាននិយាយជាមួយនឹងមនុស្សជាច្រើន ដែលមានសំណួរអំពីកម្លាំងខាងទីបន្ទាល់ផ្ទាល់ខ្លួនរបស់គេ និង ការមិនឲ្យតម្លៃដល់សមត្ថភាពខាងវិញ្ញាណរបស់គេ ដោយសារតែពួកគេមិនទទួលបាន ការបញ្ជាក់ជាញឹកញាប់ ប្រកបដោយភាពអស្ចារ្យ ឬ ជាការបញ្ជាក់ដ៏ខ្លាំងក្លា ។ ប្រហែលជាយើង ពិចារណាអំពីបទពិសោធន៍របស់យ៉ូសែប នៅព្រៃពិសិដ្ឋ ប៉ុលនៅតាមផ្លូវទៅទីក្រុងដាម៉ាស និងអាលម៉ាតូច យើងមកជឿលើអ្វីមួយដែលខុស ឬខ្វះខាតនៅក្នុងខ្លួនយើង បើសិនជាយើងគ្មានបទពិសោធន៍ដូចគ្នា និងគំរូនៃការបញ្ជាក់ខាងវិញ្ញាណដូចគ្នានេះទេ ។ បើសិនជាអ្នកមានគំនិត ឬការសង្ស័យស្រដៀងគ្នានេះ សូមទទួលស្គាល់ថា អ្នកគឺជាមនុស្សធម្មតា ។ សូមបន្តដើរឆ្ពោះទៅមុខដោយការគោរពប្រតិបត្តិ និងសេចក្តីជំនឿទៅលើព្រះអង្គសង្គ្រោះ ។ នៅពេលអ្នកធ្វើដូច្នោះ អ្នក « មិនអាចធ្វើខុសឡើយ » ( គ. និង ស. 80:3 ) ។

ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានផ្តល់ដំបូន្មានថា ៖ « សូមបង្ហាញដល់ខ្ញុំនូវពួកបរិសុទ្ធដែលត្រូវតែពឹងផ្អែក ទៅលើអព្ភូតហេតុ ទីសំគាល់ និង ការនិមិត្ត ដើម្បីរក្សាខ្លួនពួកគេឲ្យឈររឹងមាំនៅក្នុងសាសនាចក្រ ហើយ ខ្ញុំនឹងបង្ហាញដល់អ្នកនូវសមាជិក ... ដែលឈរមិនល្អនៅចំពោះមុខព្រះ ហើយដែលកំពុងតែដើរនៅលើផ្លូវរអិល ។ មិនមែនតាមរយៈការបង្ហាញប្រកបដោយអព្ភូតហេតុចំពោះយើង ដែលធ្វើឲ្យយើងនឹងស្ថាបនានៅលើសេចក្តីពិតនោះទេ ប៉ុន្តែតាមរយៈការបន្ទាបខ្លួន និងការគោរពប្រតិបត្តិដោយស្មោះត្រង់ចំពោះព្រះបញ្ញត្តិ និងច្បាប់របស់ព្រះវិញ » ( *Conference Report* ខែ មេសា ឆ្នាំ 1900 ទំព័រ 40 ) ។

បទពិសោធន៍ សាមញ្ញមួយទៀតនឹងពន្លឺ ជួយយើងឲ្យរៀនសេចក្តីពិតបន្ថែមទៀតអំពីគំរូនៃវិវរណៈ « មួយបន្ទាត់ម្តងៗ មួយសិក្ខាបទម្តងៗ » ។ ពេលខ្លះព្រះអាទិត្យរះនៅពេលព្រឹក ដែលមានពពកច្រើន ឬ ចុះអ័ព្ទ ។ ដោយសារតែស្ថានភាពមេឃស្រទំ នោះការមើលឃើញពន្លឺមានការពិបាកខ្លះៗ ហើយមិនអាចមើលឃើញគ្រាដែលព្រះអាទិត្យរះឡើងនៅជើងមេឃបានទេ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅព្រឹកនោះ យើងអាចទទួលបានពន្លឺគ្រប់គ្រាន់ដើម្បីដឹងថាជាថ្ងៃថ្មី ហើយអាចធ្វើកិច្ចការរបស់យើងបាន ។

ស្រដៀងគ្នានេះដែរ យើងទទួលវិវរណៈជាច្រើនគ្រា ដោយមិនបានដឹងច្បាស់ថា តាមរបៀបណា ឬពេលណាដែលយើងកំពុងតែទទួលវិវរណៈនោះទេ ។ មានព្រឹត្តិការណ៍សំខាន់មួយមកពីប្រវត្តិសាស្ត្រសាសនាចក្របានបង្ហាញអំពីគោលការណ៍នេះ ។

នៅនិទាឃៈរដូវឆ្នាំ 1829 អូលីវើរ ខៅឌើរី គឺជាគ្រូបង្រៀននៅ ភូមិប៉ាលម៉ៃរ៉ា រដ្ឋនូវយោក ។ នៅពេលគាត់រៀនអំពីយ៉ូសែប ស្ម៊ីធ ហើយធ្វើការក្នុងការបកប្រែព្រះគម្ពីរមរមន នោះអូលីវើរ បានទទួលអារម្មណ៍បញ្ជាក់ថា ឲ្យផ្តល់ជំនួយដល់ព្យាការីវ័យក្មេងរូបនេះ ។ ជាលទ្ធផល គាត់បានធ្វើដំណើរទៅកាន់ភូមិហារម៉ូនី ទីក្រុង ផែនស៊ីវ៉ាញ៉ា ហើយបានក្លាយទៅជាអ្នកសរសេររបស់យ៉ូសែប ។ ការទៅដល់ និងជំនួយរបស់គាត់ មានសារៈសំខាន់ចំពោះការកើតមាននៃព្រះគម្ពីរមរមន ។

ក្រោយមក ព្រះអង្គសង្គ្រោះបានបើកសម្តែងដល់អូលីវើរថា ដរាបណាដែលគាត់អធិស្ឋានសុំការដឹកនាំជាញឹកញាប់ នោះគាត់បានទទួលការដឹកនាំមកពីព្រះវិញ្ញាណនៃព្រះអម្ចាស់ ។ ព្រះអម្ចាស់បានប្រកាសថា « បើសិនជាពុំនោះសោតទេ អ្នកនឹងពុំបានមកដល់ទីដែលអ្នកនៅពេលនេះឡើយ ។ មើលចុះអ្នកដឹងហើយថា អ្នកបានសុំពីយើង ហើយយើងបានបំភ្លឺគំនិតរបស់អ្នក ហើយឥឡូវនេះ យើងប្រាប់អ្នកនូវការណ៍ទាំងឡាយនេះ ដើម្បីឲ្យអ្នកបានដឹងថា អ្នកត្រូវបានបំភ្លឺដោយព្រះវិញ្ញាណនៃសេចក្តីពិត » ( គ. និង ស. 6:14–15 ) ។

ហេតុដូច្នោះហើយ អូលីវើរ បានទទួលវិវរណៈមួយ តាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ ប្រាប់ឲ្យគាត់ដឹងថា គាត់កំពុងតែទទួលវិវរណៈ ។ តាមពិត អូលីវើរ មិនស្គាល់ថា គាត់កំពុងតែបានទទួលការដឹកនាំមកពីព្រះ ហើយត្រូវការការណែនាំនេះ ដើម្បីបង្កើនការយល់ដឹងរបស់គាត់អំពីវិញ្ញាណនៃវិវរណៈដោយរបៀបណា និងពេលណាទេ ។ ដូច្នេះ អូលីវើរ បានដើរនៅក្នុងពន្លឺ នៅពេលព្រះអាទិត្យរះនៅពេលព្រឹកស្រទំ ។

នៅក្នុងភាពមិនច្បាស់លាស់ និងឧបសគ្គជាច្រើន ដែលយើងបានជួបនៅក្នុងជីវិតរស់នៅរបស់យើង ព្រះតម្រូវឲ្យយើងខំដោយអស់ពីសមត្ថភាព ដើម្បីធ្វើទង្វើ ពុំមែនទទួលទង្វើនោះទេ ( នីហ្វៃទី 2 2:26 ) ហើយទុកចិត្តទៅលើទ្រង់ ។ យើងមិនអាចមើលឃើញទេវតា ស្តាប់ឮសម្លេងពីស្ថានសួគ៌ ឬទទួលបានការបញ្ជាក់ដ៏រន្ធត់ខាងវិញ្ញាណនោះទេ ។ យើងជារឿយៗអាចខំឆ្ពោះទៅមុខដោយក្តីសង្ឃឹម និងការអធិស្ឋាន — ប៉ុន្តែដោយគ្មានការអះអាងទាំងស្រុងនោះទេ — ដែលយើងកំពុងតែធ្វើកិច្ចការស្របទៅតាមព្រះទ័យរបស់ព្រះ ។ ប៉ុន្តែនៅពេលយើងគោរពសេចក្តីសញ្ញារបស់យើង ហើយរក្សាព្រះបញ្ញត្តិទាំងឡាយ នៅពេលយើងព្យាយាមធ្វើល្អ ហើយប្រែក្លាយជាមនុស្សកាន់តែល្អ ដោយខ្ជាប់ខ្ជួន នោះយើងអាចដើរដោយមានទំនុកចិត្តថា ព្រះនឹងដឹកនាំជំហានរបស់យើង ។ ហើយយើងអាចនិយាយដោយការអះអាងថា ព្រះនឹងបំផុសពាក្យសំដីរបស់យើង ។ រឿងនេះមានអត្ថន័យមួយចំណែកនៅក្នុងព្រះគម្ពីរដែលប្រកាសថា ៖ « ខណៈនោះអ្នកនឹងមានចិត្តក្លាហានឡើង នៅចំពោះវត្តមាននៃព្រះ » ( គ. និង ស. 121:45 ) ។

នៅពេលអ្នកស្វែងរកដោយអំណរគុណ ហើយអនុវត្តវិញ្ញាណនៃវិវរណៈ នោះខ្ញុំសន្យាថា អ្នកនឹង « ដើរនៅក្នុងពន្លឺនៃព្រះអម្ចាស់ » ( អេសាយ 2:5 នីហ្វៃទី 2 12:5 ) ។ នៅពេលខ្លះ វិញ្ញាណនៃវិវរណៈនឹងប្រតិបត្តិភ្លាមៗ ហើយប្រកបដោយថាមពល ពេលខ្លះទៀតដោយស្រទន់ និងបន្តិចម្តងៗ ហើយជាញឹកញាប់ដោយសម្លេងតិចបំផុត ដែលអ្នកមិនអាចទាំងដឹងផង ។ ប៉ុន្តែមិនថាតាមគំរូណាទេ ពរជ័យនេះគឺត្រូវបានទទួល ហើយពន្លឺដែលវាផ្តល់ឲ្យនឹងចែងចាំង ហើយបំពេញព្រលឹងរបស់អ្នក បំភ្លឺដល់ការយល់ដឹងរបស់អ្នក ( សូមមើល អាលម៉ា 5:7; អាលម៉ា 32:28 ) ហើយដឹកនាំ និងការពារអ្នក និងក្រុមគ្រួសារអ្នក ។

ខ្ញុំសូមប្រកាសធ្វើជាសាក្សីក្នុងនាមសាវកថា ព្រះវរបិតា និង ព្រះរាជបុត្រាមានព្រះជន្មរស់ ។ វិញ្ញាណនៃវិវរណៈគឺមានពិត —ហើយអាច និងធ្វើការក្នុងជីវិតរស់នៅយើងម្នាក់ៗ និងនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ខ្ញុំសូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតទាំងនេះ នៅក្នុងព្រះនាមដ៏ពិសិដ្ឋ នៃព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។